# ជូនចំពោះ មិត្តអ្នកអានគេហទំព័រទស្សនាវដ្ដី សារព័ត៌មានសេរី

ពីខ្ញុំ: សួន សេរីរដ្ឋា

ខ្ញុំបានអានប្រតិកម្មរបស់មិត្តអ្នកអាន ដែលបានលើកឡើងជជែកអំពីអត្ថបទវិភាគរបស់ខ្ញុំដែលទាក់ទងរវាងជីវិត សម្ដេច នរោត្តម សីហនុ និង របបនយោបាយខ្មែរ សម្រាប់ពេលអនាគត ។ ខ្ញុំអាចយល់បានថាមិត្តអ្នកអានមានចេតនាថាខ្ញុំសរសេរអត្ថបទប្រឌិត កុហកខុសពីការពិតនៃពូជពង្សវង្សស្ដេចត្រសក់ផ្អែម ដែលបន្តវង្សត្រកូលមកដល់ពេលបច្ចុប្បន្ននេះ ។

ខ្ញុំសូមបញ្ជាក់ថា អត្ថបទរបស់ខ្ញុំគ្រាន់តែចង់ឆ្លុះបញ្ចាំង និងធ្វើការបង្ហាញសច្ចៈភាព នៅក្នុងតថៈភាព ដែលអ្នកដឹកនាំខ្មែរគ្រប់ជំនាន់ព្យាយាមលាក់ទុកជាយូរយាណាស់មកហើយតែប៉ុណ្ណោះ ។ សច្ចៈភាព ក្នុងប្រវត្តិសាស្ត្រខ្មែរមិនដូចគ្នាទេទៅនិងតថៈភាព នៃការប្រឌិតដែលអ្នកដឹកនាំខ្មែរបានធ្វើឡើង ដោយយកការមិនពិតអោយទៅជាពិត ហើយយកការពិតទៅលាក់កប់ទុកចោលមិនអោយកូនខ្មែរដឹង ។

ខ្ញុំសូមបញ្ជាក់ថា ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរអំពីការចាប់កកើតនៃរាជ្យវង្សត្រសក់ផ្អែម ដែលពូជពង្សស្ដេចនាពេលបច្ចុប្បន្ននេះ គឺខ្ញុំសំអាងលើឯកសារចំនួនបី ដែលខ្ញុំសូមលើកជាលក្ខណៈសង្ខេបដូចតទៅ៖

១. «ប្រវត្តិសាស្ត្រប្រទេសកម្ពុជា» សិក្សាស្រាវជ្រាវដោយលោក អាដេម៉ារ ឡឺក្លែរ អតីតៈរ៉េស៊ីដង់បារាំងប្រចាំប្រទេសកម្ពុជា ។ ឯកសាបោះពុម្ពឆ្នាំ ១៩១៤ និងតំដល់ទុកដោយបណ្ណាគារក្រុងប៉ារីស ប្រទេសបារាំង ។

......... ទាំងស្ដេច នរោត្តម និងទាំងអ្នកអង្គម្ចាស់ទាំងឡាយបានទទួលស្គាល់ការពិតនៃប្រភពដើមនេះ និងនិយាយទទួលស្គាល់ថា រាជ្យវង្សបច្ចុប្បន្នចេញមកពីវង្សតាត្រសក់ផ្អែម ឬតាចាយ ដែលបានធ្វើឃាតស្ដេច រួចរៀបអភិសេកជាមួយបុត្រីស្ដេច។ ...... ក្នុងពង្សសាវតាខ្មែរបានដូរព្រះនាមព្រះរាជា រាជវង្សវរ្ម័នចំនួនពីរអង្គចុងក្រោយមកដាក់បន្លំជាឈ្មោះព្រះនាមដើម្បីភ្ជាប់ខ្សែស្រឡាយមកជាមួយនឹងស្ដេចត្រសក់ផ្អែម ។ នោះគឺគេដូរព្រះនាមព្រះរាជា ព្រះបាទស្រីន្ទ្រវរ្ម័ន មកជាព្រះបាទ សេនកៈរាជ និងដូរព្រះនាមព្រះរាជា ព្រះបាទជ័យវរ្ម័នបរមេស្វរៈ មកជាព្រះបាទ សីហនុរាជ ។

ហេតុអ្វីខ្មែរបាត់ដានប្រវត្តិសាស្ត្រ និងបាត់ឈ្មោះស្ដេចពីចន្លោះឆ្នាំ ១២៥០***?...***១៣០០***?*** លោក អាដេម៉ា ឡឺក្លែរ បានយកសម្មតិកម្មជាច្រើនរួមមានសិលាចរឹក, កំណត់ត្រាការទូតចិន និងពង្សសាវតាខ្មែរ មកធ្វើការផ្ទៀងផ្ទាត់ ហើយបានរកឃើញយ៉ាងត្រឹមត្រូវដូចខាងក្រោម....... ព្រះបាទជ័យវរ្ម័នបរមេស្វរៈ ឬ ព្រះបាទ សីហនុរាជ ត្រូវគេធ្វើឃាតក្នុងឆ្នាំ ១២៩០ ...... ។ ព្រោះបើបកក្រោយបន្តិច ព្រះបាទជ័យវរ្ម័នទី៧ សុគត់ ឬ

បាត់ខ្លួននៅឆ្នាំ១២០១ ។ ព្រះបាទឥន្ទ្រវរ្ម័ន ជាព្រះរាជបុត្រឡើងសោយរាជ្យបន្ត ហើយនៅសោយរាជ្យនៅឡើយនៅឆ្នាំ១២២០ ។ ក្រោយឆ្នាំ ១២២០ ព្រះរាជបុត្រព្រះអង្គព្រះនាមព្រះបាទស្រីន្ទ្រវរ្ម័ន ដែលក្នុងពង្សាវតា ដូរព្រះនាមមកថាព្រះបាទសេនក:រាជ្យ និងបន្ទាប់មកទៀតព្រះរាជបុត្រព្រះអង្គ ព្រះនាមព្រះបាទជ័យវរ្ម័នបរមេស្វរ: ដែលក្នុងពង្សាវតាដូរព្រះនាមមកថា ព្រះបាទសីហនុរាជ្យ បានឡើងសោយរាជ្យបន្តរហូតដល់ឆ្នាំ១២៩០ ត្រូវ ត្រសក់ផ្អែម ឬតាចាយ ធ្វើឃាតដណ្តើមរាជ្យ ....... ។ នៅក្នុងឆ្នាំ១២៩៦ ជីវ តាក្វាន់ សរសេរថា «ព្រះរាជាដែលកំពុងសោយរាជ្យនៅក្នុងឆ្នាំ១២៩៦ ជាបុត្រសុណិសា របស់ព្រះរាជាមុន ហើយដែលបានឡើងសោយរាជ្យដោយសារដណ្តើមរាជ្យពីរាជទាយាទមួយអង្គ» ។ បើដូច្នោះស្តេចដែលសោយរាជ្យក្នុងឆ្នាំ១២៩៦ គឺជា តាចាយ ដែលរឿងនិទានក្នុងពង្សសាវតាខ្មែរហៅថា ត្រសក់ផ្អែម ........។
ដូច្នោះពីឆ្នាំ ១២៥០ ដល់ឆ្នាំ១៣០០ ខ្មែរអត់បាត់បង់ប្រវត្តិសាស្រ្ត និងឈ្មោះស្តេចដែលសោយរាជ្យទេ តែដោយសាតែ ត្រសក់ផ្អែម រដ្ឋប្រហាសម្លាប់ព្រះរាជារាជ្យវង្សវរ្ម័ន រួចឡើងតាំងខ្លួនជាស្តេច ទើបប្រើអំណាចលុបចោលដានប្រវត្តិសាស្រ្តនេះ ហើយក៏ចម្លងយករឿង នាយត្រសក់ផ្អែម ពីភូមាយកមកជំនួសវិញ ។
*(សូមអានសៀវភៅប្រវត្តិសាស្រ្តកម្ពុជា របស់ អាដេម៉ារ ឡឺក្លែរ )*

២. កំណត់ហេតុ សមាជិកប្រតិភូការទូតចិន ជីវតា ក្វាន់ ដែលបានមកដល់ប្រទេសខ្មែរនៅចុងសតវត្សទី១៣ ក្នុងសម័យស្តេចជ្រៃករាជ្យ នាឆ្នាំ ១២៩០ ។ ឯកសាដើមបានចម្លង និងមានកម្កល់ទុកនៅបណ្ណាល័យប្រទេសបារាំង ។
...........ប្រទេសខ្មែរនៅចុងសតវត្សទី១៣គឺជាសម័យកាលវឹកវរ ដែលមានការបះបោរពីជនជាតិចាម វាយដណ្តើមយកឯករាជ្យផង និងការបះបោរពីជនជាតិសៀម ដែលមានបំណងវាយដណ្តើមយកទឹកដីបង្កើតជាប្រទេសផង..... នៅចុងសតវត្សទី១៣ ព្រះរាជាដែលកំពុងសោយរាជ្យនាពេលនោះនាឆ្នាំ១២៩៦ ជាបុត្រសុណិសារបស់ព្រះរាជាមុនដែលធ្វើគត់ព្រះរាជា និងដណ្តើមរាជ្យពីរាជទាយាទដែលមានសិទ្ធិគ្រងរាជ្យ ។ ព្រះរាជាអង្គនោះមិនមានឈាមជ័រជារាជ្យវង្សទេ តែព្រះអង្គជាជនជាតិសំរ៉ែ[1] ដែលចូលធ្វើទ័ព

---

[1] ជនជាតិសៀមបានបំភ្លៃការពិតមួយគឺនិយាយថា ប្រាសាទបន្ទាយសំរ៉ែ ដែលសាងសង់ពីខាងកើតនៃប្រាសាទអង្គធំថា ជាការសាងសង់ឡើងដោយតាចាយ ឬត្រសក់ផ្អែម ដែលមានកំណើតជាជាតិសំរ៉ែ តែតាមការពិតលោក អែម៉ូនីញេ អ្នកបុរាណវិទូអឺរ៉ុបបានបញ្ជាក់ថា ប្រសាទនេះសាងសង់មុនប្រាសាទអង្គរវត្តទៅទៀត មិនមែនសាងសង់ឡើងដោយ តាចាយ ទេ តែវាអាចជាការសាងសង់ឡើងដោយក្រុមជនជាតិសំរ៉ែ ដើម្បីបូជាដល់អាទិទេពណាមួយដែលគេគោរព ។

តាំងពីក្មេង ហើយក្រោយមកមានទំនាក់ទំនងស្នេហាជាមួយបុត្រីស្តេច ។ ពេលដែលបុត្រីស្តេចលួចព្រះខ័នរាជ្យពីព្រះបិតាយកមកអោយ ព្រះអង្គក៏ធ្វើគត់ព្រះរាជា ដែលជាបិតាក្មេក រួចឡើងធ្វើស្តេចខ្លួនឯងទៅ ។ ព្រះរាជា ដែលត្រូវ បុត្រសុណិសាធ្វើគត់មានព្រះរាជបុត្រជារាជទាយាទដែរ តែព្រះរាជទាយាទគ្មានព្រះខ័នរាជ្យនៅក្នុងដៃ ទើបមិនអាចឡើងសោយរាជ្យបាន ។ គ្រានោះព្រះរាជទាយាទ ទ្រង់បានកេណ្ឌទ័ពប្រឆាំងនឹងព្រះរាមថ្លៃ តែត្រូវព្រះរាមថ្លៃ ជាស្តេចជ្រែករាជ្យ ចាប់កាត់ម្រាមជើងចេញអស់ ជាហេតុធ្វើអោយរឹតតែគ្មានសិទ្ធិសោយរាជ្យណាស់ទៅទៀត រួចហើយត្រូវឃុំខ្លួនក្នុងគុកងងឹតរហូតសោយទីវង្គត់.............។

*(សូមអានឯកសាប្រវត្តិសាស្ត្រចិន ស្តីពីទំនាក់ទំនងការទូតជាមួយខ្មែរពីឆ្នាំ១១២៨)*

៣. កំណត់ស្រាវជ្រាវរបស់លោក ហ្វប៊ែរ អ្នកប្រាជ្ញបារាំង ដែលបានសិក្សាពីប្រភពរឿង «ត្រសក់ផ្អែម» តាំងពីកំណើតរឿងក្នុងប្រទេសឥណ្ឌា ដែលត្រូវបានប្រទេសភូមាចម្លងយកចូលក្នុងប្រទេសភូមានៅសតវត្សទី១០ ។ ឯកសារជាភាសាបារាំង និងភាសាភូមាមានតម្កល់ទុកនៅក្នុងបណ្ណាល័យជាតិប្រទេសភូមា ។

...........រឿង «ត្រសក់ផ្អែម» ដែលពង្សសាវតាខ្មែរយកមកធ្វើជាដើមប្រវត្តិសាស្ត្រនៃពូជពង្សស្តេចខ្មែរនៅពេលបច្ចុប្បន្ននេះគឺជាលំនាំរឿងនិទានតែមួយដូចគ្នានឹងរឿង «ស្តេចបីអង្គ ឬស្តេចពាល» ដែលកើតនៅប្រទេសឥណ្ឌាតាំងពី២០០ឆ្នាំ មុនសម័យពុទ្ធអង្គទៅទៀត ។ នៅក្នុងសតវត្សទី១០ ភូមា បានចម្លងរឿងនេះចូលមកក្នុងប្រទេសហើយកែចំណងថារឿង«សុចមនសារិម៉ាងសាមិចម្មាសាចព្រះធំ» ។

សូមអានអត្ថបទព្រឹត្តិបត្រភាសាបារាំងចុងបូព៌ា (Bulletin de l' Ecole Française d' Extrème-Orient) ត្រង់ផ្នែក Les Etudes Indochinoises របស់លោក ហ្វប៊ែ ក្បាលទី៥ ឆ្នាំ១៩០៥ ទំព័រទី១៧៦ ដល់ទំព័រទី១៨៤ Le Jardinier régicide qui devient roi ។

៤. ធ្វើការរៀបតាមលំដាប់ឆ្នាំនៃលំនាំកំណត់ស្រាវជ្រាវប្រវត្តិសាស្ត្រទំនើប អំពីកំណត់នៃពង្សសាវតាខ្មែរ គឺបានបង្ហាញអោយឃើញយ៉ាងច្បាស់ថា អ្នករៀបចំ ពង្សសាវតានេះមានចេតនាបំភ្លៃការពិតលុបបំបាត់ដានប្រវត្តិសាស្ត្រ ឬក៏មានចេតនាធ្វើតម្រូវចិត្តអ្នកមានអំណាចណាម្នាក់តែប៉ុណ្ណោះ ។ ពង្សសាវតាខ្មែរ ដែលមានកំណើតតាំងពីឆ្នាំ១៨៤៨ ហើយដែលខ្មែរ យកមកធ្វើជាប្រវត្តិសាស្ត្ររបស់ខ្មែរនោះគឺមានលក្ខណៈ មិនសុក្រិតទេបើធ្វើការផ្ទៀងផ្ទាត់អោយច្បាស់លាស់មែនទែន ។ ...........

ពង្សសាវតាខ្មែរ ......ស្តេចត្រសក់ផ្អែម មានបុត្រាបីនាក់មាននាមថា ព្រះស្រីសេរីបុត្រ ព្រះនិព្វានបទ និងព្រះសន្ធានរាជា ។

- ស្តេចត្រសក់ផ្អែម សោយរាជ្យបានចំនួន ១៧ឆ្នាំ ។
- អ្នកសោយរាជ្យបន្តគឺ តាសួស ដែលត្រូវជាប្អូនគឺសោយរាជ្យបានចំនួន ៥០ឆ្នាំ ក្នុងព្រះបរមនាមថា សម្តេចព្រះបរមមាយរាជា ។
- បន្ទាប់មកគឺព្រះបាទស្រីសេរីបុត្រ ជាបុត្ររបស់ស្តេចត្រសក់ផ្អែម សោយរាជ្យបានចំនួន ៣៩ឆ្នាំ ។
- ព្រះបរមលំពងរាជា ជាបុត្រព្រះបាទស្រីសេរីបុត្រ ឡើងគ្រងរាជ្យក្នុងព្រះជន១៦វស្សា ហើយសោយរាជ្យបានចំនួន ៥៥ ឆ្នាំ ។
- ព្រះបរមរាជឱង្ការ ជាបុត្រព្រះលំពងរាជា គ្រងរាជ្យក្នុងព្រះជន១៦វស្សា ហើយសោយរជ្យបានចំនួន ៦០ឆ្នាំ ។
- ព្រះស្រីសុរិយោពណ៌ ជាបុត្រព្រះបរមរាជឱង្ការ គ្រងរាជ្យក្នុងព្រះជន១៦វស្សាដែរ ហើយសោយរាជ្យបានចំនួនដល់ទៅ ៧៦ឆ្នាំ

  បន្ទាប់មកបានវិលទៅបុត្រទីពីរ និងបុត្រទីបី របស់ ស្តេចត្រសក់ផ្អែមវិញគឺ ព្រះនិព្វានរាជា និងព្រះសន្ទានរាជា ។ ក្នុងចន្លោះកាលនេះបើបូកចំនួនស្តេចដែលសោយរាជ្យតាំងពីស្តេចត្រសក់ផ្អែម ដែលជាបិតារបស់ ព្រះនិព្វានរាជា និងព្រះសន្ទានរាជាគឺមានស្តេចចំនួន៦អង្គ ហើយបើបូកចំនួនឆ្នាំដែលស្តេចទាំង៦អង្គនោះសោយរាជ្យ គឺអស់ពេលចំនួន ២៧៩ឆ្នាំ បានដល់បុត្រទីពីរ របស់ត្រសក់ផ្អែម ។ ដូច្នោះសួថា តើបុត្រស្តេចត្រសក់ផ្អែម ព្រះនិព្វានរាជា អង្គនេះមានព្រះជនលើសពី ២៧៩ វស្សាឬយ៉ាងណា ? ហើយមិនមានទេ តើពង្សសាវតា ដែលខ្មែរខំរៀនតគ្នាធ្វើជាប្រវត្តិសាស្ត្ររបស់ខ្មែរក្រោយសម័យអង្គរនោះ គឺជាការពិតដែលយកជាការបានទេ ? គួអោយជឿទេ ?

ដូច្នោះសូមមិត្តអ្នកអាន មេត្តាស្រាវជ្រាវរកសៀវភៅ និងឯកសារទាំងនោះមកអានរួចសូមសិក្សាវិភាគតាមការគួរ ទៅលើអត្ថបទរបស់ខ្ញុំដែលនិយាយទាក់ទងពីប្រវត្តិសាស្ត្រស្តីអំពីរដ្ឋប្រហាររបស់ ត្រសក់ផ្អែម ក្នុងឆ្នាំ១២៩០ ដែលសម្លាប់ផ្តាច់ពូជរាជវង្សវរ្ម័ន ហើយឡើងធ្វើជាស្តេច និងកែប្រែរបបដឹកនាំពីរាជានិយមប្រជាធិបតេយ្យ មកជារបបរាជានិយមសក្តិភូមិ ។

សូមអគុណ !